**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០១២/២៦ ក.ប/ស.ជ.ណ.ស.ជិ.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលស្គាល់ជំនាញពីមុនរបស់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការជំរុញការអភិវឌ្ឍនិងទទួលស្គាល់ជំនាញរបស់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងរៀបចំការធ្វើតេស្តទទួលស្គាល់ជំនាញពីមុន (RPL) ជូនដល់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ ដោយប្រែក្លាយបទពិសោធការងារនិងចំណេះជំនាញពីការអនុវត្តជាក់ស្តែងទៅជាលិខិតទទួលស្គាល់ជំនាញផ្លូវការ ដែលបងប្អូនអាចយកទៅប្រើប្រាស់ក្នុងការទទួលបានឱកាសការងារល្អនិងប្រាក់ចំណូលខ្ពស់ជាងមុន ចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦ តទៅ ដោយរាជរដ្ឋាភិបាលជាអ្នកបង់ថ្លៃធ្វើតេស្តជំនួស លើមុខជំនាញចំនួន ៨ ក្នុងវិស័យសំណង់ រួមមាន៖

| | | |
|---|---|---|
| ១. ការងារកំបោរ (រៀបឥដ្ឋនិងបូក) | ២. ការងារការ៉ូ | ៣. ការដំឡើងពុម្ព |
| ៤. ការដំឡើងបណ្តាញបំពង់ទឹក | ៥. ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ | ៦. ការងាររន្ទា |
| ៧. ការដំឡើងសរសៃដែក | ៨. ការផ្សារអគ្គិសនី | |

បងប្អូនអាចដាក់ពាក្យស្នើសុំចុះឈ្មោះដោយផ្ទាល់នៅមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពទាំង៩ រៀងរាល់ម៉ោងធ្វើការ (ដូចមានបញ្ជីឈ្មោះក្នុងឧបសម្ព័ន្ធ) ឬតាមរយៈប្រព័ន្ធឆ្លើយតបបន្ទាន់ (Hotline) ១២៩៧ ឬចុះតាមប្រព័ន្ធអនឡាញតាមអាសយដ្ឋាន **https://erpl.mlvt.gov.kh** ឬស្កេនឃ្យូអរកូដ ដោយភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរពលករកម្ពុជាទៅធ្វើការនៅបរទេស (TD) ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- បណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ឬលិខិតបញ្ជាក់ថាជាអតីតពលករ
- រូបថតបច្ចុប្បន្នទំហំ ៤x៦ ថតចំពីមុខ ផ្ទៃពណ៌ស ចំនួន ៣សន្លឹក។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៨៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ការធ្វើតេស្តត្រូវបានរៀបចំនៅរៀងរាល់ ថ្ងៃសុក្រ សៅរ៍ អាទិត្យ តាមពេលវេលាដូចខាងក្រោម៖

- ពេលព្រឹក៖ ចាប់ពីម៉ោង ៨:០០នាទី ដល់ ១១:០០នាទី
- ពេលរសៀល៖ ចាប់ពីម៉ោង ១:៣០នាទី ដល់ ៤:៣០នាទី
- ពេលយប់៖ ចាប់ពីម៉ោង ៥:៣០នាទី ដល់ ៨:៣០នាទី

បេក្ខជនត្រូវមកដល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពឱ្យបានយ៉ាងតិច ១ម៉ោង មុនម៉ោងធ្វើតេស្ត។

បេក្ខជនត្រូវមកបង្ហាញខ្លួននៅមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពដែលបានចុះឈ្មោះតាមការទំនាក់ទំនង ១សប្តាហ៍ មុនថ្ងៃធ្វើតេស្ត ដើម្បីពិនិត្យមើលបន្ទប់អនុវត្តតេស្ត សម្ភារៈ បរិក្ខារ និងឧបករណ៍សម្រាប់ធ្វើតេស្ត និងហាត់សម ព្រមទាំងបំពេញឯកសារពាក់ព័ន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃនិងសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងចុះឈ្មោះធ្វើតេស្តឱ្យបានផុលផុស ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃ ពុធ ៧កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

**ស្កេនចុះឈ្មោះ**

**ស្កេនទីតាំងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព**

**ចម្លងជូន៖**

- រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

## បញ្ជីឈ្មោះមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព

| ល.រ. | | គ្រឹះស្ថាន អ.ប.វ. | មុខជំនាញធ្វើតេស្ត | អាសយដ្ឋាននិង<br>លេខទំនាក់ទំនង |
|---|---|---|---|---|
| ក. រាជធានីភ្នំពេញ | | | | |
| ១ | ១ | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្តាញបំពង់ទឹក<br>៥.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ទា<br>៧.ការដំឡើងសរសៃដែក<br>៨.ការផ្សារអគ្គិសនី | **អាសយដ្ឋាន៖** ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (ក្បែរវត្តពូនភ្នំ)<br>**លេខទំនាក់ទំនង៖**<br>០១៧ ៤៤៥ ៩៦០<br>០៧០ ២០៨ ៨៥៤<br>០៩៧ ៤១៨ ៥៥៦៩ |
| ២ | ២ | វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (NTTI) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្តាញបំពង់ទឹក<br>៥.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ទា<br>៧.ការដំឡើងសរសៃដែក | **អាស័យដ្ឋាន៖** ផ្លូវសហពន្ធ័រុស្សី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>**លេខទំនាក់ទំនង៖**<br>០១២ ៩៥៧ ៦៨៤<br>០១៧ ៨៨២ ៧២៤<br>០៩៦ ៧០៦ ៦៦៧១<br>០៩៥ ៥៥៩ ៨៥៩ |
| ៣ | ៣ | វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (PPI) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្តាញបំពង់ទឹក<br>៥.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ទា<br>៧.ការដំឡើងសរសៃដែក | **អាសយដ្ឋាន៖** ផ្លូវសហព័ន្ធរុស្សី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>**លេខទំនាក់ទំនង៖**<br>០៧៧/០៨៧ ៥១៩ ១៥១<br>០៧៨ ៦៥៦ ៥៧៤<br>០១៦ ៣៩៣ ០៧៩ |

| ល.រ. | | គ្រឹះស្ថាន អ.ប.វ. | មុខជំនាញធ្វើតេស្ត | អាសយដ្ឋាននិង<br>លេខទំនាក់ទំនង |
|---|---|---|---|---|
| ៤ | ៤ | វិទ្យាស្ថាន<br>បច្ចេកទេស<br>ឧស្សាហកម្ម<br>(ITI) | ការផ្សារអេគ្គិសនី | **អាសយដ្ឋាន៖** ផ្លូវសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>**លេខទំនាក់ទំនង៖**<br>០៨៧ ៣៧២ ៧៣២<br>០៨១ ៤២១ ៧៤៤<br>០៨៥ ៨០៤ ០០៥ |
| **ខ. ខេត្តសៀមរាប** | | | | |
| ៥ | ១ | វិទ្យាស្ថានជាតិ<br>ពហុបច្ចេកទេស<br>អង្គរ (NPIA) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្តាញបំពង់ទឹក<br>៥.ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ទា<br>៧.ការដំឡើងសរសៃដែក | **អាសយដ្ឋាន៖** ភូមិព្រៃគុយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប<br>**លេខទំនាក់ទំនង៖**<br>០១២ ២២៥ ១១៣<br>០៩០ ៤៩៩ ៧៧៧<br>០១២ ៥៩៦ ៤៦៦<br>០៧០ ៩១៦ ០៣០<br>០៨១ ៧១៩ ៦៦២<br>០៦៣ ២១០ ៧៩៨ |
| **គ. ខេត្តស្វាយរៀង** | | | | |
| ៦ | ១ | វិទ្យាស្ថាន<br>ពហុបច្ចេកទេស<br>ភូមិភាគតេជោ<br>សែនស្វាយរៀង<br>(RPITSSR) | ការផ្សារអេគ្គិសនី | **អាសយដ្ឋាន៖** ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>**លេខទំនាក់ទំនង៖**<br>០១២ ២៦៧ ៦៧៩<br>០១២ ៨៩២ ២៤៩<br>០១២ ៥២១ ៣៧៥<br>០៨៨ ៩៥៣ ២៣៣៣<br>០១០ ៨១៦ ៦៩៩ |

| ល.រ. | | គ្រឹះស្ថាន អ.ប.វ. | មុខជំនាញធ្វើតេស្ត | អាសយដ្ឋាននិង<br>លេខទំនាក់ទំនង |
|---|---|---|---|---|
| ៧ | ១ | វិទ្យាស្ថាន<br>បច្ចេកវិទ្យា<br>បាត់ដំបង (BIT) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្ដាញបំពង់ទឹក<br>៥.ការដំឡើងបណ្ដាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ធា<br>៧.ការដំឡើងសរសៃដែក<br>៨.ការផ្សារអគ្គិសនី | **អាសយដ្ឋាន៖** ភូមិរំចេក៤<br>សង្កាត់រតនៈ ក្រុងបាត់ដំបង<br>ខេត្តបាត់ដំបង<br>**លេខទំនាក់ទំនង៖**<br>០១៦ ៥២២ ២០៦<br>០៩៦ ៥៥៥៥ ៩៤១<br>០១២ ៨៦៣ ៧៦១<br>០៩៣ ៣០៥ ៨៨៥<br>០៧១ ៣១៧ ៣៥៣៥<br>០១០ ៥១៥ ១០៧ |
| **ង. ខេត្តបន្ទាយមានជ័យ** | | | | |
| ៨ | ១ | វិទ្យាស្ថាន<br>ពហុបច្ចេកទេស<br>ខេត្តបន្ទាយ<br>មានជ័យ<br>(PIBMC) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្ដាញបំពង់ទឹក<br>៥.ការដំឡើងបណ្ដាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ធា<br>៧.ការដំឡើងសរសៃដែក | **អាសយដ្ឋាន៖** ភូមិគាប<br>សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ<br>ខេត្តបន្ទាយមានជ័យ<br>**លេខទំនាក់ទំនង៖**<br>០១៧ ៧៥០ ៥០៥<br>០៩៥ ៨៩០ ០២៦<br>០៩២ ៣៥៨ ២៥៨<br>០៩២ ៨៦១ ៣៦៦ |
| **ច. ខេត្តតាកែវ** | | | | |
| ៩ | ១ | វិទ្យាស្ថាន<br>ពហុបច្ចេកទេស<br>ភូមិភាគតេជោ<br>សែនតាកែវ<br>(RPITST) | ១.ការងារកំបោរ<br>២.ការងារការ៉ូ<br>៣.ការដំឡើងពុម្ព<br>៤.ការដំឡើងបណ្ដាញបំពង់ទឹក<br>៥.ការដំឡើងបណ្ដាញអគ្គិសនីក្នុងអគារ<br>៦.ការងាររន្ធា<br>៧.ការដំឡើងសរសៃដែក<br>៨.ការផ្សារអគ្គិសនី | **អាសយដ្ឋាន៖** ភូមិ៣<br>សង្កាត់រកាក្នុង ក្រុងដូនកែវ<br>ខេត្តតាកែវ<br>**លេខទំនាក់ទំនង៖**<br>០៣២ ២១០ ១០២<br>០៧៧ ៨៥៧ ៥១៨<br>០១៦ ៤៧៧ ៧៨២<br>០១២ ៧៣៣ ៣០៤ |